ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០៩១ ស្សប្រក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ស្ថានភាពក្រោយបទឈប់បាញ់ គិតពីម៉ោង១រសៀល ដល់ម៉ោង៦ល្ងាច ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

គិតចាប់ពីម៉ោង១រសៀល ដល់ម៉ោង៦ល្ងាច ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥នេះ វីរយុទ្ធជនកម្ពុជា និងយោធាថៃ **បានអនុវត្តបទឈប់បាញ់** ធ្វើឱ្យស្ថានភាពស្ងប់ស្ងាត់ ពលរដ្ឋភៀសសឹកបានវិលត្រឡប់ទៅលំនៅឋានវិញជាបណ្តើរៗ ជាពិសេសវីរកងទ័ពទាំង១៨រូប បានធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព ស្របតាមសេចក្តីប្រកាសរួម នៃកិច្ចប្រជុំពិសេសលើកទី៣ គណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ (GBC) នៅច្រកព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។

**១-ស្ថានភាពពលរដ្ឋភៀសសឹក៖** របាយការណ៍បឋម បើគិតពីម៉ោង១រសៀល ដល់ម៉ោង៦ល្ងាចថ្ងៃនេះ មានជនភៀសសឹក**៥៥.៥៩៦**នាក់ បានបន្តវិលត្រឡប់ទៅលំនៅឋានវិញ ខណៈ**ខេត្តកោះកុង** ពុំមានជនភៀសសឹកបន្តស្នាក់នៅក្នុងជំរំសុវត្ថិភាពទៀតទេ ដែលធ្វើឱ្យជនភៀសសឹកនៅសល់សរុបមានចំនួន ៥១៧.៥៥៥នាក់ ក្នុងនោះស្ត្រី ២៦៩.៩៥៤នាក់ និងកុមារ១៦១.៩៨៩នាក់។

**២-ការបន្តបិទផ្អាក និងការដំណើរការឡើងវិញសេវាសាធារណៈជាមូលដ្ឋាន៖ ខេត្តបន្ទាយមានជ័យ** មានសាលារៀន៣២១កន្លែង (រដ្ឋ២៣៧ ឯកជន៨៤) និងមន្ទីរពេទ្យ/មណ្ឌលសុខភាព៧កន្លែងបន្តបិទផ្អាក ខណៈសាលារៀន៩កន្លែង មន្ទីរពេទ្យ/មណ្ឌលសុខភាព១៥កន្លែង និងរដ្ឋបាលនៅថ្នាក់ខេត្ត ក្រុង ស្រុក និងឃុំ-សង្កាត់ បានដំណើរការឡើងវិញ។ **ខេត្តព្រះវិហារ** មានសាលារៀន៦១កន្លែង និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១៤កន្លែងនៅបន្តបិទផ្អាក ខណៈរដ្ឋបាលនៅថ្នាក់ស្រុក១ និងឃុំចំនួន៦ បានដំណើរការឡើងវិញ។ **ខេត្តឧត្តរមានជ័យ** មានសាលារៀន២១៨កន្លែង មន្ទីរពេទ្យ/មណ្ឌលសុខភាព១៤កន្លែង រដ្ឋបាលនៅថ្នាក់ខេត្ត១ ក្រុង-ស្រុក២ ឃុំ-សង្កាត់៩ និងប៉ុស្តិ៍នគរបាលរដ្ឋបាល១កន្លែងបានបន្តបិទផ្អាក ខណៈសាលារៀន៤២កន្លែង មន្ទីរពេទ្យ/មណ្ឌលសុខភាព៤កន្លែង រដ្ឋបាលស្រុក៣ អង្គភាពកងកម្លាំងមានសមត្ថកិច្ច១០ រដ្ឋបាលឃុំ១៥ និងប៉ុស្តិ៍នគរបាលរដ្ឋបាល២៣កន្លែង បានដំណើរការឡើងវិញ។ ចំពោះ **ខេត្តកោះកុង** មានសាលារៀន៦២កន្លែងបានបើកដំណើរការឡើងវិញ ក្នុងចំណោមសាលារៀន៦៦កន្លែង ដែលបានបិទផ្អាក។

**៣-កិច្ចអន្តរាគមន៍រៀបចំផ្ទះសំបែង និងភូមិករពលរដ្ឋភៀសសឹក៖ ខេត្តឧត្តរមានជ័យ** មានពលរដ្ឋ១១.៦៣០គ្រួសារ ស្មើនឹងមនុស្សចំនួន៣៩.៧៥០នាក់ បានវិលចូលរស់នៅក្នុងផ្ទះសំបែងឡើងវិញ មានភូមិចំនួន៨៤ពុំទាន់អាចឱ្យពលរដ្ឋចូលទៅរស់នៅបាន និងភូមិចំនួន១៧២ទៀត ត្រូវបានអាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធចុះរៀបចំផ្ទះសំបែងជូនពលរដ្ឋរួចរាល់។ **ខេត្តបន្ទាយមានជ័យ** មានពលរដ្ឋចំនួន២៩.៣៥៧គ្រួសារ ស្មើនឹងមនុស្សចំនួន១១០.៩២៤នាក់ និង**ខេត្តព្រះវិហារ** មានពលរដ្ឋ២.៣០៣គ្រួសារ ស្មើនឹងមនុស្សចំនួន៨.៩៦០នាក់ បានវិលចូលរស់នៅក្នុងផ្ទះសំបែងឡើងវិញ។ ជារួម **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ-សង្កាត់ បានកំពុងបន្តយកចិត្តទុកដាក់ពិនិត្យ និងដោះស្រាយកិច្ចការអាទិភាពជាច្រើនទៀត ដើម្បីធានាការវិលមករកប្រក្រតីភាព នៃសេវាសាធារណៈជាមូលដ្ឋាននៅតាមបណ្តាក្រុង ស្រុក និងឃុំ-សង្កាត់ ជាពិសេសក្នុងខេត្តជាប់ព្រំដែន

ដែលបានបិទផ្អាកក្នុងរយៈកាលកន្លងមក។ ជាមួយគ្នានេះ ក៏បាននិងកំពុងខិតខំបង្កលក្ខណៈជូនជនភៀសសឹកធាប់បានវិលត្រឡប់ទៅលំនៅឋានវិញប្រកបដោយសុវត្ថិភាព។ ក្នុងនោះរួមទាំងការដោះស្រាយបញ្ហាចំពោះមុខសម្រាប់ផ្ទះសំបែង និងភូមិករពលរដ្ឋដែលរងការខូចខាត ការបោសសម្អាតយុទ្ធភណ្ឌមិនទាន់ផ្ទុះ ទន្ទឹមនឹង**ការពិនិត្យនិងបន្តហាមឃាត់ការបង្ហោះអាកាសយានគ្មានមនុស្សបើក(ដ្រូន)** គ្រប់ទីកន្លែង គ្រប់ពេលវេលា រហូតដល់មានការណែនាំថ្មី។

ពាក់ព័ន្ធនឹងការវិវត្តចុងក្រោយក្នុងដំណើរស្វែងរកសន្តិភាព **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមប្រកាសគាំទ្រជំហរដ៏មោះមុត និងច្បាស់លាស់របស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ដែលបានគូសបញ្ជាក់ថា **ការអនុវត្តបទឈប់បាញ់ មិនមែនជាការចុះចាញ់ ឬយកបូរណភាពទឹកដី និងអធិបតេយ្យជាតិ ទៅដោះដូរយកសន្តិភាពនោះឡើយ។** ផ្ទុយទៅវិញ គឺឈរលើគោលការណ៍រក្សាការពារអាយុជីវិតប្រជាពលរដ្ឋ និងការពារអធិបតេយ្យជាតិ ក្នុងមាគ៌ាសន្តិវិធីស្របតាមច្បាប់អន្តរជាតិ ដើម្បីបញ្ចប់អរិភាពរវាងប្រទេសទាំងពីរ។ សូមជនរួមជាតិ ជឿជាក់លើរាជរដ្ឋាភិបាល រួបរួមស្មារតីជាតិខ្មែរតែមួយ និងត្រូវយកការលំបាកនេះធ្វើជាឱកាស ដើម្បីឱ្យខ្មែរគ្រប់រូបចេះពួតដៃគ្នាកសាងជាតិយើងឱ្យកាន់តែរឹងមាំ និងកាន់តែប្រសើរឡើង។ ទន្ទឹមគ្នានេះ **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** មានក្តីស្ងប់ស្ងែងយ៉ាងក្រៃលែងចំពោះមនុញ្ញផលថ្មីមួយទៀតនៃការអនុវត្តយុទ្ធសាស្ត្រ «**ស្ងាត់តែមិនស្ងៀម**» របស់រាជរដ្ឋាភិបាល គឺការធ្វើមាតុភូមិនិវត្តន៍នៃវីរកងទ័ពកម្ពុជាទាំង១៨រូប ប្រកបដោយសុវត្ថិភាព និងកិត្តិយស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥នេះ។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមគោរពថ្លែងអំណរគុណ និងគាំទ្រយ៉ាងស្មោះស្ម័គ្រចំពោះ **សម្តេចតេជោ ហ៊ុន សែន** និង **សម្តេចធិបតី ហ៊ុន ម៉ាណែត** ដែលបានដាក់ចេញយុទ្ធសាស្ត្រការពារជាតិយ៉ាងត្រឹមត្រូវ ធ្វើឱ្យប្រជាជនកម្ពុជា ទាំងក្នុង និងក្រៅប្រទេស កាន់តែទទួលបានអារម្មណ៍កក់ក្តៅ ដែលមានប្រតិបត្តិករ គឺវីរយុទ្ធជនជួរមុខឈរជើងយ៉ាងរឹងមាំអង់អាចជាញជ័យ រយៈពេល**២០យប់ ២១ថ្ងៃ** ការពារអធិបតេយ្យជាតិ និងប្រជាជន។ **យើងទាំងអស់គ្នា សូមបន្ទន់កាយ សង្រួមចិត្ត គោរពវិញ្ញាណក្ខន្ធវីរយុទ្ធជនពលី និងសូមចូលរួមទទួលអារម្មណ៍ឈឺចាប់ និងក្តីមោទនជាមួយក្រុមគ្រួសារ។** យើងក៏សូមជូនពរវីរយុទ្ធជន ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យឆាប់បានជាសះស្បើយ។ សូមជនរួមជាតិ បន្តស្មារតីព្រលឹងខ្មែរតែមួយជានិរន្តរ៍រៀងទៅ។

ថ្ងៃពុធ ១២កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥